# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៥-១២-២០១៦ -ព្រះរាជក្រម នស/រកម/១២១៦/០១៩ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ១០៣២៥


### ២~ព្រះរាជក្រឹត្យ


០១-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១០៤ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំដល់លោក **ទិត្យ សន** "TITH SAN" ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដែលបច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ១០៣៦៦

០២-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១០៥ ស្តីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ **គឹម សុខា** ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ពីបទបដិសេធក្នុងការចូលខ្លួន តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១៣០"ក្រ I. សវ" ១០៣៦៧

០៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១០៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១៣ រូប ១០៣៦៨

០៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១០៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **ម៉ែត្យូ យ៉ូសេប** (MATTHEWS JOSEPH) ជនជាតិប៉ាគីស្ថាន សញ្ជាតិប៉ាគីស្ថាន ១០៣៧០


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៣-១២-២០១៦-អនុក្រឹត្យលេខ ១២១៦ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ១០៣៧១

១៤-១២-២០១៦ -អនុក្រឹត្យលេខ ១២១៧ អនក្រ.តត ស្តីពី ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ ១០៣៧៣

១៤-១២-២០១៦ -អនុក្រឹត្យលេខ ១២១៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០៣៧៤

១៤-១២-២០១៦ -អនុក្រឹត្យលេខ ១២១៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០៣៧៥
១៥-១២-២០១៦ -អនុក្រឹត្យលេខ ១២២០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ១០៣៧៧
១៥-១២-២០១៦ -អនុក្រឹត្យលេខ ១២២១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ១០៣៧៩
១៥-១២-២០១៦ -អនុក្រឹត្យលេខ ១២២២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១០៣៨០
១៦-១២-២០១៦ -អនុក្រឹត្យលេខ ១២២៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០៣៨២
១៩-១២-២០១៦ -អនុក្រឹត្យលេខ ១២២៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ១០៣៨៣
១៩-១២-២០១៦ -អនុក្រឹត្យលេខ ១២២៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៣៨៧
១៩-១២-២០១៦ -អនុក្រឹត្យលេខ ១២២៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៣៩៤
១៩-១២-២០១៦ -អនុក្រឹត្យលេខ ១២២៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៣៩៧
១៩-១២-២០១៦ -អនុក្រឹត្យលេខ ១២២៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៤០០

## ២_បទបញ្ជា

០៦-១២-២០១៦ -បទបញ្ជាលេខ ០២ បប ស្តីពី ការអនុវត្តផែនការស្តីពីការទប់ស្កាត់ និងដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញាឆ្នាំ ២០១៦-២០១៩ ១០៤០១

# ព្រះរាជក្រម

នស/រកម/១២១៦/០១៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពី
# ហិរញ្ញវត្ថុសម្រាប់ការ
# គ្រប់គ្រងឆ្នាំ ២០១៧

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## ថវិកាថ្នាក់ជាតិ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ២០ ១៨៤ ៤៥៧ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត..................................................១៥ ៥០១ ៤៦៩ លានរៀល
- ចំណូលមូលធន..................................................៤ ៦៨២ ៩៨៨ លានរៀល
  - \+ ចំណូលមូលធនក្នុងប្រទេស..................................១៤៨ ៤៣១ លានរៀល
  - \+ ចំណូលមូលធនក្រៅប្រទេស..................................៤ ៥៣៤ ៥៥៧ លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ..................................................២៥០ ០០០ លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ..................................................៤ ២៨៤ ៥៥៧ លានរៀល ។

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ត្រូវបានកំណត់ស្មើនឹង ២០ ១៨៤ ៤៥៧ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត.................................................. ១៣ ០៥០ ៦៨៦ លានរៀល
- ចំណាយមូលធន.................................................. ៧ ១៣៣ ៧៧១ លានរៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស
..................................................២ ១៨៣ ៧០០ លានរៀល

- ដោយថវិកាថ្នាក់ជាតិ..................................១ ៩៣៣ ៧០០ លានរៀល

- គម្រោងវិនិយោគផ្ទាល់.............. ១ ៤៣៧ ៦០០ លានរៀល
- បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស ..........................................៤៩៦ ១០០ លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ..........................................................២៥០ ០០០ លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ..........................................................៤ ២៨៤ ៥៥៧ លានរៀល

គ- ការទូទាត់ការខ្ចី.........................................៦៦៥ ៥១៤ លានរៀល ។

**មាត្រា ៣.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ត្រូវបានកំណត់ស្មើនឹង ១៣ ០៥០ ៦៨៦ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៩ ត្រូវបានកំណត់ស្មើនឹង ២៤ ៦៤០ ៤៩៤ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា............................ ៧ ១៣៣ ៧៧១ លានរៀល
- ឥណទានទូទាត់................................. ៧ ១៣៣ ៧៧១ លានរៀល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា............................... ២ ១៨៣ ៧០០ លានរៀល
- ឥណទានទូទាត់.................................... ២ ១៨៣ ៧០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា............................... ៤ ២៨៤ ៥៥៧ លានរៀល
- ឥណទានទូទាត់.................................... ៤ ២៨៤ ៥៥៧ លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា.................................. ៦៦៥ ៥១៤ លានរៀល
- ឥណទានទូទាត់.......................................៦៦៥ ៥១៤ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗដូចមានចែងក្នុងតារាង "**គ២**" និង"**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៦.-**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ដែលបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ ហិរញ្ញប្បទាន |
|---|---|---|
| I. ចំណូលក្នុងប្រទេសសរុប | ១៥ ៦៤៩ ៩០០ | |
| ១. ចំណូលចរន្ត | ១៥ ៥០១ ៤៦៩ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ១៤៨ ៤៣១ | |
| II. ចំណាយថវិកាសរុប | ១៩ ៥១៨ ៩៤៣ | |
| ១. ចំណាយចរន្ត | ១៣ ០៥០ ៦៨៦ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៦ ៤៦៨ ២៥៧ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ២ ១៨៣ ៧០០ | |
| + ដោយថវិកាថ្នាក់ជាតិ | ១ ៩៣៣ ៧០០ | |
| - គម្រោងវិនិយោគផ្ទាល់ | ១ ៤៣៧ ៦០០ | |
| - បដិភាគវិនិយោគ | ៤៩៦ ១០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | ២៥០ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ២៨៤ ៥៥៧ | |
| អតិរេកនៃថវិកាចរន្ត ( I.១ -II.១ ) | | +២ ៤៥០ ៧៨៣ |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II) | | -៣ ៨៦៩ ០៤៣ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៣ ៨៦៩ ០៤៣ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៨៦៩ ០៤៣ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +២៥០ ០០០ |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៤ ២៨៤ ៥៥៧ |
| • ការទូទាត់ការខ្ចី | | -៦៦៥ ៥១៤ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | 0 |
| • បញ្ញើរាជរដ្ឋាភិបាល | | 0 |



## ជំពូកទី ២

## ការខ្ចី និងការធានារបស់រដ្ឋ

### មាត្រា ៧.-

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត ៧០០ ០០០ ០០០ SDR (ប្រាំពីររយលានអេសដេអ៊ែរ) ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភា និងព្រឹទ្ធសភារៀងរាល់ ៦ ខែម្តង ។

### មាត្រា ៨.-

មិនអនុញ្ញាតឲ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងលក្ខខណ្ឌ ទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

## ជំពូកទី ៣

## បទប្បញ្ញត្តិស្តីពីពន្ធដារ

### មាត្រា ៩.-

ពាក្យមួយចំនួននៅក្នុងច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់ត្រូវបានកែសម្រួលដូចខាងក្រោម ៖

១- ពាក្យ "ប្រាក់ចំណេញ" ត្រូវបានជំនួសដោយពាក្យ "ប្រាក់ចំណូល"

២- ពាក្យ "របបពិត" ត្រូវបានជំនួសដោយពាក្យ "របបស្វ័យប្រកាស"

៣- ពាក្យ "ឆ្នាំសារពើពន្ធ" ត្រូវបានជំនួសដោយពាក្យ "ឆ្នាំជាប់ពន្ធ"

៤- ពាក្យ "ក្រុមអាជីវកម្ម" ត្រូវបានជំនួសដោយពាក្យ "ក្រុមហ៊ុនសហកម្មសិទ្ធិ"

៥- ពាក្យ "ក្រុមហ៊ុនដើមទុន" ត្រូវបានជំនួសដោយពាក្យ "ក្រុមហ៊ុនមូលធន"

៦- ពាក្យ "កថាខណ្ឌ៤" ក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ២ នៃមាត្រា ១៣ថ្មី ត្រូវបានជំនួសដោយពាក្យ "កថាខណ្ឌ៣"

៧- ពាក្យ "ចំនួន ៧៥ ០០០ រៀល (ប្រាំពីរម៉ឺនប្រាំពាន់រៀល)" ក្នុងវាក្យខណ្ឌ ក និង វាក្យខណ្ឌ ខ នៃកថាខណ្ឌ២ នៃមាត្រា៤៦ ត្រូវបានជំនួសដោយពាក្យ "ចំនួន ១៥០ ០០០ រៀល (មួយរយហាសិបពាន់រៀល)"

៨- ពាក្យ "ស្ថាប័នសញ្ញ័យធន និងស្ថាប័នឥណទាន" ក្នុងកថាខណ្ឌ៤ នៃមាត្រា ៦ថ្មី និងពាក្យ "ឬស្ថាប័នសញ្ញ័យធន" ក្នុងកថាខណ្ឌ១ និងពាក្យ "និងស្ថាប័នសញ្ញ័យធន" ក្នុងកថាខណ្ឌ២ នៃមាត្រា ២៥ថ្មី នៃច្បាប់នេះត្រូវបានលុបចេញ

៩- ពាក្យ "ប្រធាន" ក្នុងមាត្រា១១៨ មាត្រា១២០ និងមាត្រា១៣៤ ត្រូវបានជំនួសដោយពាក្យ "អគ្គនាយកនៃ" និងពាក្យ "នាយកដ្ឋានពន្ធដារ" ត្រូវបានជំនួសដោយពាក្យ "អគ្គ-នាយកដ្ឋានពន្ធដារ" ។

## មាត្រា ១០.-

ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់ត្រូវបានកែសម្រួលដូចខាងក្រោម ៖

**មាត្រា ៣ ថ្មី** ត្រូវបានកែសម្រួលកថាខណ្ឌ៣ កថាខណ្ឌ៤ កថាខណ្ឌ៥ កថាខណ្ឌ៧ កថាខណ្ឌ៨ និងកថាខណ្ឌ៩ និងត្រូវបានបន្ថែមកថាខណ្ឌ១៣ កថាខណ្ឌ១៤ និងកថាខណ្ឌ១៥ ដូចខាងក្រោម ៖

៣- ពាក្យ "នីតិបុគ្គល" សំដៅដល់សហគ្រាស ឬអង្គការនានា ដែលប្រកបអាជីវកម្ម ទោះបីជាបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី ។ ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរនូវក្រុមហ៊ុនមូលធន ស្ថាប័នរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ អង្គការមិនស្វែងរកចំណេញ ឬគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជន ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពាក្យ "នីតិបុគ្គល" ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនសហកម្មសិទ្ធិ ឬសហគ្រាសឯកបុគ្គល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះ បុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន ។ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរនូវបណ្តាញ ឬរូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះបុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។ គ្រឹះស្ថានអចិន្ត្រៃយ៍ត្រូវបានចាត់ទុកជានីតិបុគ្គលនិវាសនជនចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ ។

៥- ពាក្យ "ក្រុមហ៊ុនសហកម្មសិទ្ធិ" សំដៅដល់សហគ្រាសដែលបង្កើតឡើងដោយរូបវន្តបុគ្គលពីរ ឬច្រើននាក់ ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ឬចំណេះដឹង ឬសកម្មភាពរបស់រូបវន្តបុគ្គលទាំងនោះដើម្បីប្រកបអាជីវកម្មរួមគ្នា ។ ក្នុងនិយមន័យនេះ ក្រុមហ៊ុនសហកម្មសិទ្ធិ រួមមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ ក្រុមហ៊ុនសហកម្មសិទ្ធិមិនអាចជាសមាជិករបស់ក្រុមហ៊ុនសហកម្មសិទ្ធិណាមួយ ហើយក៏មិនរាប់បញ្ចូលផងទេនូវក្រុមហ៊ុនមូលធន គ្រឹះស្ថានអចិន្ត្រៃយ៍ ឬសហគ្រាសឯកបុគ្គល ។

៧- ពាក្យ "អាជីវកម្ម" សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលក្នុងគោលដៅផលិត និងលក់ទំនិញ ផ្គត់ផ្គង់សេវា ភតិសន្យា ជួលឬលក់ទ្រព្យសម្បត្តិឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័ន ឬអង្គការនានា ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រានេះ ។

៨- ពាក្យ "ភាគលាភ" សំដៅដល់ចំណែកជាសាច់ប្រាក់ ឬជាទ្រព្យ ដែលនីតិបុគ្គលបានចែកឲ្យអ្នកចូលហ៊ុនទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួននៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែការបែងចែកមូលធន ឬដើមទុនក្នុងពេលជម្រះបញ្ជីរំលាយក្រុមហ៊ុន ។ ចំណែកណាមួយដែលចាត់ទុកថាជាភាគលាភឬមិនមែនជាភាគលាភ ត្រូវផ្អែកតាមលក្ខខណ្ឌខាងលើនេះដោយពុំគិតថា នីតិបុគ្គលមាន ឬគ្មានប្រាក់ចំណូលសុទ្ធក្នុងឆ្នាំចរន្ត ឬពីឆ្នាំមុនៗឡើយ ។

៩- ពាក្យ "អ្នកចូលហ៊ុន" សំដៅដល់បុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ។ សម្រាប់គោលដៅនៃពន្ធនេះ នីតិបុគ្គលណាមួយ ទោះបីមិនមែនជាក្រុមហ៊ុនមូលធនក្តី ត្រូវចាត់ទុកដូចជាក្រុមហ៊ុនមូលធន ហើយបុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ឬក៏បុគ្គលអាចបានទទួលប្រាក់ចំណូលក្នុងឋានៈជាអ្នកបានចូលរួមក្នុងនីតិបុគ្គលនោះត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនរបស់នីតិបុគ្គលដែរ ។

១៣- ពាក្យ "ធនាគារ" សំដៅដល់អង្គភាពណាមួយដែលអនុវត្តជាប្រក្រតីនូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការដូចខាងក្រោម ៖

ក. ផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជនដោយមានកម្រៃ រាប់បញ្ចូលទាំងឥណទានភតិសន្យា

ខ. ទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន

គ. ប្រព្រឹត្តកម្មនិងការដាក់ឲ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឬជារូបិយបណ្ណ ។

១៤- ពាក្យ "ប្រាក់ចំណូលដុល" សំដៅដល់ប្រាក់ចំណូលមិនទាន់កាត់កងចំណាយ ដែលបានមកពីប្រតិបត្តិការនានា ដែលជាសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ ។

១៥- ពាក្យ "ប្រាក់ចំណូលសុទ្ធ" សំដៅដល់លទ្ធផលបានមកពីការយកប្រាក់ចំណូលដុលកាត់កងនូវចំណាយនានាដែលអនុញ្ញាតដោយច្បាប់នេះ ។

### មាត្រា ២០ ..ថ្មី (មួយ)

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានដូចតទៅ ៖

១- ២០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល ។

២- ៣០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំង ព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ។

៣- ០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៤- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឲ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ៖

| ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ១២ ០០០ ០០០ ៛ | ០% |
| ពី | ១២ ០០០ ០០១ ៛ | ដល់ | ១៨ ០០០ ០០០ ៛ | ៥% |
| ពី | ១៨ ០០០ ០០១ ៛ | ដល់ | ១០២ ០០០ ០០០ ៛ | ១០% |
| ពី | ១០២ ០០០ ០០១ ៛ | ដល់ | ១៥០ ០០០ ០០០ ៛ | ១៥% |
| | | លើសពី | ១៥០ ០០០ ០០០ ៛ | ២០% |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ២១ ..ថ្មី

ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រងត្រូវបានកំណត់ដូចតទៅ ៖

១- ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់ស្មើនឹង ៥ ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុល ដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ។

២- ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និងសកម្មភាពដទៃទៀតក្រៅពីធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់តាមមាត្រា ២០ថ្មី (មួយ) នៃច្បាប់នេះ ។

វិធាននិងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ២២ ..ថ្មី

ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេសត្រូវបានកំណត់ដូចខាងក្រោម ៖

១- ប្រាក់ចំណូលដែលសម្រេចបានពីប្រភពកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមមាត្រា ២០ថ្មី (មួយ) នៃច្បាប់នេះ ។

២- ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធចរន្ត សាខាក្រុមហ៊ុនបរទេសណាមួយធ្វើការផ្ទេរប្រាក់ចំណូលប្រភពកម្ពុជាទៅក្រៅប្រទេស ប្រាក់ចំណូលនោះ ៖

ក. មិនត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភតាមមាត្រា ២៣ថ្មី (មួយ) នៃច្បាប់នេះទេ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលក្រោយការបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា ២០ថ្មី (មួយ) នៃច្បាប់នេះ

ខ. ត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភតាមកថាខណ្ឌ១ នៃមាត្រា ២៣ថ្មី (មួយ) នៃច្បាប់នេះ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលដែលមិនបានបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា ២០ថ្មី (មួយ) នៃច្បាប់នេះ និង

គ. ត្រូវជាប់ពន្ធកាត់ទុកតាមមាត្រា ២៦ថ្មី (មួយ) លើប្រាក់ចំណូលដូចមានចែងក្នុងកថាខណ្ឌ១០ នៃមាត្រា៣៣ថ្មី នៃច្បាប់នេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

វិធាន និងនីតិវិធីនៃការប្រមូលប្រាក់ពន្ធតាមមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២៣ ..ថ្មី (មួយ)

ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ ត្រូវបានកំណត់ដូចតទៅ ៖

១- រាល់ការបែងចែកភាគលាភ ត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ ។ ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភសម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានកំណត់ស្មើនឹងលម្អៀងរវាងប្រាក់ពន្ធត្រូវបង់តាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា ២០ថ្មី (មួយ) នៃច្បាប់នេះ និងប្រាក់ពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់ជាក់ស្តែងសម្រាប់ឆ្នាំជាប់ពន្ធនោះ ។

២- ប្រសិនបើសហគ្រាសណាមួយបានទទួលភាគលាភបានបង់ពន្ធតាមកថាខណ្ឌ១ នៃមាត្រានេះ ពីសហគ្រាសមួយទៀតត្រូវកត់ត្រាចំនួនប្រាក់ភាគលាភនោះទៅក្នុងគណនីភាគលាភរបស់ខ្លួន ។ ពេលសហគ្រាសនោះបែងចែកភាគលាភជាបន្តទៀតទៅអ្នកចូលហ៊ុនរបស់ខ្លួន ទឹកប្រាក់បែងចែកដែលត្រូវដកចេញពីគណនីភាគលាភមិនត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ ដូចក្នុងកថាខណ្ឌ១ នៃមាត្រានេះទេ ។

មាត្រា ២៤ ..ថ្មី (ពីរ)

ពន្ធអប្បបរមាត្រូវបានកំណត់ស្មើនឹង ១ ភាគរយ នៃផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម ។ ពន្ធអប្បបរមាត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលដែលបានបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ តាមវិធានដែលមានចែងក្នុងមាត្រា ៣៧ថ្មី មាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់នេះ ។ ពន្ធអប្បបរមាត្រូវបានកំណត់លើសហគ្រាសទាំងឡាយណាដែលមិនកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ ។

លក្ខណៈវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ និងនីតិវិធីក្នុងការបង់ពន្ធអប្បបរមា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២៦ ..ថ្មី (មួយ)

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម រួមទាំងគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជន ដែលធ្វើការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងមាត្រា ៣៣ថ្មី នៃច្បាប់នេះ ឲ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវកាត់ទុកនិងបង់នូវប្រាក់ពន្ធតាមអត្រា១៤ ភាគរយ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

នៃទឹកប្រាក់ត្រូវបើក ។ ពន្ធកាត់ទុកនេះ មិនត្រូវអនុវត្តចំពោះបុព្វលាភធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជានោះទេ ។

មាត្រា ២៩ -.ថ្មី

អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំត្រូវមានកាតព្វកិច្ចដូចខាងក្រោម ៖

១- អនុវត្តកាតព្វកិច្ចបញ្ជិកាគណនេយ្យដូចមានចែងក្នុងមាត្រា ៦ថ្មី នៃច្បាប់នេះ និងត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ៣ ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗដោយភ្ជាប់ជាមួយនូវតារាងតុល្យការ គណនីលទ្ធផល និងព័ត៌មានបន្ថែម ។

២- ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទនិងក្នុងរយៈពេលដូចគ្នាដែរ ។

មាត្រា ៣០ -.ថ្មី

អ្នកជាប់ពន្ធតូចត្រូវមានកាតព្វកិច្ចដូចខាងក្រោម ៖

១- ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំក្នុងរយៈពេល ៣ ខែ ក្រោយដំណាច់ឆ្នាំប្រតិទិននីមួយៗតាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន ។

២- ក្នុងករណីមិនបានកាន់កត់ត្រាបញ្ជីចំណូលចំណាយតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ចំនួនប្រាក់ចំណូលជាប់ពន្ធត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យ និងគណនាតាមអត្រាចំណូលទៅតាមមុខរបរអាជីវកម្ម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៤៧ -.ថ្មី (មួយ)

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ដូចតទៅ ៖

| ភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ១ ០០០ ០០០ ៛ | ០% |
| ពី | ១ ០០០ ០០១ ៛ | ដល់ | ១ ៥០០ ០០០ ៛ | ៥% |
| ពី | ១ ៥០០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១០% |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២០% |



**មាត្រា ៥៧** ត្រូវបានបន្ថែមកថាខណ្ឌ ៨ កថាខណ្ឌ ៩ កថាខណ្ឌ ១០ និងកថាខណ្ឌ ១១ ដូចខាងក្រោម ៖

៨- សេវាសិក្សាអប់រំ ។

៩- ថាមពលអគ្គិសនីនិងទឹកស្អាត ។

១០- ផលិតផលកសិកម្មមិនទាន់កែច្នៃ ។

១១- សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ ។

**មាត្រា ៩៩ ..ថ្មី**

ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាមួយ ឬដើម្បីប្រមូលពន្ធ ឬដើម្បីបំពេញលក្ខខណ្ឌតម្រូវនានាស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ រដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជន រួមទាំងធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀតឲ្យ ៖

- ផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធ ដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ

- បង្ហាញខ្លួនទៅតាមពេលវេលា និងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹង ដើម្បីផ្តល់ព័ត៌មាន និងដើម្បីបង្ហាញ ឬផ្តល់ឯកសារ ឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង ។

បន្ថែមលើព័ត៌មានដែលបានតម្រូវដូចមានចែងនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ លិខិតជូនដំណឹងត្រូវមានចុះឈ្មោះ និងលេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធ ព្រមទាំងឈ្មោះ ហត្ថលេខា និងត្រារបស់រដ្ឋបាលសារពើពន្ធដែលចេញលិខិតជូនដំណឹង ។

**មាត្រា ១១.–**

មាត្រា ១៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ត្រូវបានកែប្រែដូចតទៅ ៖

**ពន្ធប្រថាប់ត្រា** ត្រូវបានលើកលែង និងអនុគ្រោះដូចខាងក្រោម ៖

១- ត្រូវបានលើកលែងពន្ធប្រថាប់ត្រាចំពោះ ៖

- ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល
- ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងវង្សញាតិ

-ការទទួលកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ សេះ ។

២- ត្រូវបានអនុគ្រោះពន្ធប្រថាប់ត្រាចំពោះការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងវង្វង់ញាតិ ។

វិធាន និងនីតិវិធីស្តីពីការលើកលែងនិងអនុគ្រោះពន្ធ ដូចមានចែងក្នុងមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## និយ័តភាពឧបនីយកម្មនៃកិច្ចប្រតិបត្តិការ
## ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦

**មាត្រា ១២.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ទឹកប្រាក់ចំនួន ៨២ ០០០ ០០០ ០០០ រៀល(ប៉ែតសិបពីរប៊ីលានរៀលគត់) ដើម្បីផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទ សម្រាប់អនុវត្តកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាលក្នុងការជំរុញស្ថិរភាពការូបនីយកម្មថ្លៃស្រូវ និងជំរុញការទិញស្រូវក្នុងស្រុក ។

## ជំពូកទី ៥

## ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ១៣.-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា ៣៥ និងមាត្រា ៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ចំណូល-ចំណាយថវិការបស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ សរុបចំនួន ១ ៦០៥ ៧១៤ លានរៀល ត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

**ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត**

- ចំណូលថវិកាសរុប................................. ១ ០៨៥ ២៣៩ លានរៀល
  - +ចំណូលចរន្តសរុប.....................................៩៥៦ ៥២៩ លានរៀល
    - -ចំណូលសារពើពន្ធ........................... ៩២៦ ៣០០ លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ....................៣០ ២២៩ លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ................. ១២៨ ៧១០ លានរៀល
    - -ឧបត្ថម្ភរាជធានី ខេត្ត.......................... ១២០ ៧១០ លានរៀល
    - -ឧបត្ថម្ភសេវាអនាម័យបរិស្ថាន............... ៨ ០០០ លានរៀល ។
- ចំណាយថវិកាសរុប.............................. ១ ០៨៥ ២៣៩ លានរៀល
  - +ចំណាយចរន្ត........................................ ៧៧២ ៨១៧ លានរៀល
  - +ចំណាយមូលធន......................................២១៩ ០៥៩ លានរៀល
  - +អតិរេករាជធានី ខេត្ត.............................. ៩៣ ៣៦៣ លានរៀល ។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ក២**" និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗ និងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ខ២**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក**

- ចំណូលថវិកាសរុប...................................១៤៥ ០៧២ លានរៀល
  - +ចំណូលចរន្តសរុប..................................... ១០ ៩៩៩ លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ.................... ១០ ៩៩៩ លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ.............១៣៤ ០៧៣ លានរៀល ។
- ចំណាយថវិកាសរុប..................................១៤៥ ០៧២ លានរៀល
  - +ចំណាយចរន្ត..........................................១៤៤ ៩៩៦ លានរៀល
  - +ចំណាយមូលធន............................................ ៧៦ លានរៀល ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

**គ.ថវិការបស់រដ្ឋបាលឃុំ សង្កាត់**

- ចំណូលថវិកាសរុប.................................. ៣៧៥ ៤០៣ លានរៀល

  +ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប................៣៧៥ ៤០៣ លានរៀល

  -ចំណូលសង្កាត់ចំណុះរាជធានី............២៥ ៣៦៥,៩ លានរៀល

  -ចំណូលសង្កាត់ចំណុះក្រុង.................២៩ ៥២៩,៧ លានរៀល

  -ចំណូលឃុំ.............................. ៣២០ ៥០៧,៤ លានរៀល ។

- ចំណាយថវិកាសរុប................................. ៣៧៥ ៤០៣ លានរៀល

  +ចំណាយសរុប....................................... ៣៧៥ ៤០៣ លានរៀល

  -ចំណាយសង្កាត់ចំណុះរាជធានី...........២៥ ៣៦៥,៩ លានរៀល

  -ចំណាយសង្កាត់ចំណុះក្រុង............... ២៩ ៥២៩,៧ លានរៀល

  -ចំណាយឃុំ.............................៣២០ ៥០៧,៤ លានរៀល ។

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៥.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១៦

នស.រកម.១២១៦.០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

លេខ:១១៤៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ការគ្រប់គ្រងឆ្នាំ២០១៧

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិកាថ្នាក់ជាតិ (I+II) | | | | 17.612.477,0 | 20.184.457,0 | 2.571.980,0 | 14,6% |
| I. សរុបចំណូលឆ្លងកាត់រតនាគារជាតិ (ក+ខ) | | | | 13.741.127,0 | 15.899.900,0 | 2.158.773,0 | 15,7% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 13.538.127,0 | 15.649.900,0 | 2.111.773,0 | 15,6% |
| ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២) | | | | 13.407.263,0 | 15.501.469,0 | 2.094.206,0 | 15,6% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 13.407.263,0 | 15.501.469,0 | 2.094.206,0 | 15,6% |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | | 11.555.055,0 | 13.209.100,0 | 1.654.045,0 | 14,3% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 9.409.455,0 | 11.009.500,0 | 1.600.045,0 | 17,0% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 2.647.310,0 | 3.276.600,0 | 629.290,0 | 23,8% |
| | | 70011 | ពន្ធលើប្រាក់ចំណូល (រូបវន្តបុគ្គល) | 96.800,0 | 210.000,0 | 113.200,0 | 116,9% |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 1.881.110,0 | 2.190.000,0 | 308.890,0 | 16,4% |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 502.500,0 | 620.600,0 | 118.100,0 | 23,5% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 124.100,0 | 200.000,0 | 75.900,0 | 61,2% |
| | | 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (នីតិបុគ្គល) | 42.800,0 | 56.000,0 | 13.200,0 | 30,8% |
| | 7002 | | ពន្ធប្រយោល | 4.121.050,0 | 4.574.400,0 | 453.350,0 | 11,0% |
| | | 70021 | អាករលើផលរបរ | 33.050,0 | | -33.050,0 | -100,0% |
| | | 70022 | អាករលើតម្លៃបន្ថែម | 1.488.000,0 | 1.745.000,0 | 257.000,0 | 17,3% |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 685.000,0 | 750.000,0 | 65.000,0 | 9,5% |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 1.669.000,0 | 1.835.000,0 | 166.000,0 | 9,9% |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល ទំនិញជាសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) | 246.000,0 | 244.400,0 | -1.600,0 | -0,7% |
| | 7003 | | អាករពិសេស | 2.594.600,0 | 3.060.000,0 | 465.400,0 | 17,9% |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 619.500,0 | 700.000,0 | 80.500,0 | 13,0% |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 339.000,0 | 360.000,0 | 21.000,0 | 6,2% |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 1.563.400,0 | 1.920.000,0 | 356.600,0 | 22,8% |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 72.700,0 | 80.000,0 | 7.300,0 | 10,0% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 46.495,0 | 98.500,0 | 52.005,0 | 111,9% |
| | | 70081 | ពន្ធតែមប្រិ៍ | 7.975,0 | 8.500,0 | 525,0 | 6,6% |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 38.520,0 | 90.000,0 | 51.480,0 | 133,6% |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.145.600,0 | 2.199.600,0 | 54.000,0 | 2,5% |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.034.000,0 | 2.149.800,0 | 115.800,0 | 5,7% |
| | | 71001 | ពន្ធគយពីការនាំចូល | 1.350.000,0 | 1.430.000,0 | 80.000,0 | 5,9% |
| | | 71002 | កម្រៃពីការងារគយ | 66.000,0 | 72.600,0 | 6.600,0 | 10,0% |
| | | 71003 | ពន្ធគយលើផលិតផលគេលសិលា | 305.000,0 | 320.000,0 | 15.000,0 | 4,9% |
| | | 71004 | អាករបន្ថែមលើផលិតផលគេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 275.000,0 | 288.000,0 | 13.000,0 | 4,7% |
| | | 71005 | ផលនៃការលក់ផ្ទែកគយ | 1.000,0 | 1.000,0 | | |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 35.000,0 | 36.000,0 | 1.000,0 | 2,9% |
| | | 710[illegible] | ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) | 2.000,0 | 2.200,0 | 200,0 | 10,0% |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 111.600,0 | 49.800,0 | -61.800,0 | -55,4% |
| | | [illegible]011 | អាករលើការនាំចេញឈើ | 75.000,0 | 14.000,0 | -61.000,0 | -81,3% |
| | | 71[illegible]12 | អាករលើការនាំចេញកៅស៊ូ | 33.000,0 | 33.000,0 | | |
| | | [illegible]4 | អាករលើការនាំចេញទំនិញផ្សេងៗ | 2.900,0 | 2.300,0 | -600,0 | -20,7% |
| | | [illegible] | ពិន័យផ្សេងៗពីការនាំចេញ | 700,0 | 500,0 | -200,0 | -28,6% |

# ការគ្រប់គ្រងឆ្នាំ២០១៧

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ទឹកប្រាក់ | ភាគរយ |
| | | | **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | **1.852.208,0** | **2.292.369,0** | **440.161,0** | **23,8%** |
| 72 | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** | **103.901,6** | **109.767,5** | **5.865,9** | **5,6%** |
| | 7200 | | ផលនៃសម្បទាន និងការជួលដីធ្លី | 88.082,0 | 91.121,5 | 3.039,5 | 3,5% |
| | | 72001 | សម្បទាននេសាទ | 3.055,0 | 2.650,0 | -405,0 | -13,3% |
| | | 72002 | សម្បទានព្រៃឈើ | 20.000,0 | 16.028,0 | -3.972,0 | -19,9% |
| | | 72003 | សម្បទានពីប្រេងកាត | 2.564,2 | 400,0 | -2.164,2 | -84,4% |
| | | 72004 | សម្បទានរ៉ែ | 34.800,7 | 55.625,3 | 20.824,6 | 59,8% |
| | | 72005 | ការជួលដីទំនេរ (មានតែដី) | 27.662,1 | 16.418,2 | -11.243,9 | -40,6% |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | 15.819,6 | 18.646,0 | 2.826,4 | 17,9% |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 15.751,0 | 18.545,0 | 2.794,0 | 17,7% |
| | | 72014 | ប្រាក់ធានារ៉ាប់រងសង្គម | 68,6 | 101,0 | 32,4 | 47,2% |
| 73 | | | **ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា** | **1.657.096,7** | **1.948.335,8** | **291.239,1** | **17,6%** |
| | 7300 | | ផលទុនសហគ្រាសសាធារណៈរដ្ឋបាល សេវាដំណើរការ(រកចំណេញ) | 545.483,1 | 724.172,0 | 178.688,9 | 32,8% |
| | | 73001 | ផលទុនរបស់អាកាសចរណ៍ស៊ីវិល | 107.000,0 | 120.110,0 | 13.110,0 | 12,3% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 270.687,9 | 398.090,9 | 127.403,0 | 47,1% |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 27.044,0 | 43.131,0 | 16.087,0 | 59,5% |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 133.635,0 | 155.565,8 | 21.930,8 | 16,4% |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 1.736,1 | 1.233,0 | -503,1 | -29,0% |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 30,0 | 32,0 | 2,0 | 6,7% |
| | | 73008 | ផលទុនផ្សេងៗទៀត | 5.350,1 | 6.009,3 | 659,2 | 12,3% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 37.280,6 | 84.839,4 | 47.558,8 | 127,6% |
| | | 73011 | ការលក់សម្ភារៈបរិក្ខារ សម្ភារៈខូចខាត សម្ភារៈសិក្សា | 122,0 | 124,0 | 2,0 | 1,6% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 36.968,9 | 84.598,4 | 47.629,5 | 128,8% |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | 189,7 | 117,0 | -72,7 | -38,3% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 670.770,7 | 733.108,0 | 62.337,3 | 9,3% |
| | | 73021 | អាកាស្តោនទូត (លិខិតឆ្លងដែននិងទិដ្ឋាការ) | 506.778,0 | 568.906,0 | 62.128,0 | 12,3% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 17.926,0 | 23.274,2 | 5.348,2 | 29,8% |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 6.428,0 | 9.176,0 | 2.748,0 | 42,8% |
| | | 73025 | ផលពីការលក់ស្លាកលេខ | 32.945,0 | 12.418,9 | -20.526,1 | -62,3% |
| | | 73026 | ចំណូលពីប្រដាប់ក្ដី | 3.273,5 | 3.635,6 | 362,1 | 11,1% |
| | | 73027 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាននិងសេវាត្រួតពិនិត្យអនាម័យសត្វ | 101.322,9 | 113.694,9 | 12.372,0 | 12,2% |
| | | 73028 | ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទំរង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 2.097,3 | 2.002,4 | -94,9 | -4,5% |
| | 7303 | | ការជួលទ្រព្យសម្បត្តិអចល័ត | 21.602,3 | 19.685,1 | -1.917,2 | -8,9% |
| | | 73031 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្ដាល | 4.781,4 | 5.147,5 | 366,1 | 7,7% |
| | | 73032 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់ខេត្ត (មន្ទីរជំនាញ) | 9,6 | 9,6 | | |
| | | 73033 | ការជួលសម្ភារៈ និងមធ្យោបាយដឹកជញ្ជូន | 2,9 | 2,4 | -0,5 | -17,2% |
| | | [illegible] | [illegible]ជួលអចលនវត្ថុ (អសង្ហារឹម) | 16.808,4 | 14.525,6 | -2.282,8 | -13,6% |
| | [illegible] | | [illegible]សេវាកម្ម | 96.483,6 | 82.451,2 | -14.032,4 | -14,5% |
| | | 73042 | កម្រៃនៃ[illegible]ថែទាំ | 18.914,0 | 8.614,5 | -10.299,5 | -54,5% |
| | | [illegible] | សេវា[illegible]យោធី | 25.903,6 | 30.550,0 | 4.646,4 | 17,9% |
| | | 73044 | សេវា[illegible]ផ្លាង | 6.673,4 | 9.800,0 | 3.126,6 | 46,9% |
| | | 73045 | សេវា[illegible]ខិតប្ដោលទោស | 1.809,0 | 1.918,8 | 109,8 | 6,1% |

## ការគ្រប់គ្រងឆ្នាំ២០១៧

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ទឹកប្រាក់ | ភាគរយ |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 43.183,6 | 31.567,9 | -11.615,7 | -26,9% |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | 285.476,4 | 304.080,1 | 18.603,7 | 6,5% |
| | | 73061 | ចំណូលភាគពួកិច្ចពីកាស៊ីណូ | 133.550,0 | 151.750,0 | 18.200,0 | 13,6% |
| | | 73062 | ចំណូលភាគពួកិច្ចពីឆ្នោត | 1.300,0 | 1.430,0 | 130,0 | 10,0% |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 26.851,4 | 25.400,1 | -1.451,3 | -5,4% |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 123.775,0 | 125.500,0 | 1.725,0 | 1,4% |
| 74 | | | ចំណូលពីការផាកពិន័យ ការដាក់ទណ្ឌកម្ម និងការរឹបអូសប្រាក់កក់ | 10.537,2 | 29.905,9 | 19.368,7 | 183,8% |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 10.537,2 | 29.905,9 | 19.368,7 | 183,8% |
| 75 | | | ការឧបត្ថម្ភ អំណោយ | 1.915,5 | 131.938,8 | 130.023,3 | 6788,0% |
| | 7506 | | ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ | 693,0 | | -693,0 | -100,0% |
| | | 75061 | ពីក្រសួង ស្ថាប័ន | 693,0 | | -693,0 | -100,0% |
| | 7508 | | ចំណូលចរន្តពីប្រភពផ្សេងៗ | 1.222,5 | 131.938,8 | 130.716,3 | 10692,5% |
| 76 | | | ផលហិរញ្ញវត្ថុ | 78.757,0 | 72.421,0 | -6.336,0 | -8,0% |
| | 7601 | | ការប្រាក់នៃការឲ្យខ្ចី | 78.748,0 | 72.421,0 | -6.327,0 | -8,0% |
| | | 76011 | ការប្រាក់លើកម្ចី | 78.748,0 | 72.421,0 | -6.327,0 | -8,0% |
| | 7698 | | ផលហិរញ្ញវត្ថុផ្សេងទៀត | 9,0 | | -9,0 | -100,0% |
| ខ.សរុបចំណូលមូលធន (ក្រុមទី១ + ក្រុមទី២) | | | | 333.864,0 | 398.431,0 | 64.567,0 | 19,3% |
| ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២) | | | | 333.864,0 | 398.431,0 | 64.567,0 | 19,3% |
| ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់ | | | | 130.864,0 | 148.431,0 | 17.567,0 | 13,4% |
| 27 | | | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 130.864,0 | 148.431,0 | 17.567,0 | 13,4% |
| | 2701 | | ការអោយខ្ចី (ការសងវិញនូវមូលធន) | 130.864,0 | 148.431,0 | 17.567,0 | 13,4% |
| | | 27011 | ការឲ្យខ្ចី ទៅសហគ្រាសសាធារណៈ | 130.864,0 | 148.431,0 | 17.567,0 | 13,4% |
| ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ | | | | 203.000,0 | 250.000,0 | 47.000,0 | 23,2% |
| 75 | | | ការឧបត្ថម្ភអំណោយ | 41.000,0 | 88.000,0 | 47.000,0 | 114,6% |
| | 7515 | | ឧបត្ថម្ភកធនមូលធនពីក្រៅប្រទេសពហុភាគីសម្រាប់ចំណាយវិនិយោគិន | 41.000,0 | 88.000,0 | 47.000,0 | 114,6% |
| 50 | | | ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល | 162.000,0 | 162.000,0 | | |
| | 5002 | | ការខ្ចីក្រៅប្រទេស-ពហុភាគី | 162.000,0 | 162.000,0 | | |
| II. សរុបចំណូលអនុវត្តក្រៅរតនាគារជាតិ (ក+ខ) | | | | 3.871.350,0 | 4.284.557,0 | 413.207,0 | 10,7% |
| ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ | | | | 3.871.350,0 | 4.284.557,0 | 413.207,0 | 10,7% |
| 75 | | | ការឧបត្ថម្ភ អំណោយ | 541.989,0 | 599.838,0 | 57.849,0 | 10,7% |
| | 7514 | | ឧបត្ថម្ភកធនមូលធនពីក្រៅប្រទេសទ្វេភាគីសម្រាប់ចំណាយវិនិយោគ | 541.989,0 | 599.838,0 | 57.849,0 | 10,7% |
| 50 | | | ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល | 3.329.361,0 | 3.684.719,0 | 355.358,0 | 10,7% |
| | 5002 | | ការខ្ចីក្រៅប្រទេស-ពហុភាគី | 3.329.361,0 | 3.684.719,0 | 355.358,0 | 10,7% |



## ការគ្រប់គ្រងឆ្នាំ២០១៧

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត (ក+ខ) | | | | 914.635,0 | 1.085.239,0 | 170.604,0 | 18,7% |
| ក-សរុបចំណូលចរន្ត (ក្រុមទី១+ក្រុមទី២) | | | | 914.635,0 | 1.085.239,0 | 170.604,0 | 18,7% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី ១+ប្រភេទទី ២) | | | | 914.635,0 | 1.085.239,0 | 170.604,0 | 18,7% |
| ប្រភេទទី ១: ចំណូលសារពើពន្ធ | | | | 777.504,0 | 926.300,0 | 148.796,0 | 19,1% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 777.504,0 | 926.300,0 | 148.796,0 | 19,1% |
| | 7003 | | អាករពិសេស | 134.482,0 | 161.205,0 | 26.723,0 | 19,9% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 134.482,0 | 161.205,0 | 26.723,0 | 19,9% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 17.665,0 | 19.329,0 | 1.664,0 | 9,4% |
| | | 70045 | អាករលើការស្នាក់នៅ | 15.158,0 | 17.369,0 | 2.211,0 | 14,6% |
| | | 70046 | ពន្ធសត្តឃាត | 2.507,0 | 1.960,0 | -547,0 | -21,8% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តន៍សកម្មភាព | 180.282,0 | 230.057,0 | 49.775,0 | 27,6% |
| | | 70053 | ពន្ធប៉ាតង់ | 33.123,0 | 43.788,0 | 10.665,0 | 32,2% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 147.159,0 | 186.269,0 | 39.110,0 | 26,6% |
| | 7006 | | ពន្ធប្រថាប់ត្រា | 338.077,0 | 401.645,0 | 63.568,0 | 18,8% |
| | | 70061 | ពន្ធប្រថាប់ត្រាលើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ | 323.623,0 | 383.630,0 | 60.007,0 | 18,5% |
| | | 70062 | ពន្ធប្រថាប់ត្រាលើតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ | 4.302,0 | 7.453,0 | 3.151,0 | 73,2% |
| | | 70063 | ពន្ធប្រថាប់ត្រាលើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 2.349,0 | 562,0 | -1.787,0 | -76,1% |
| | | 70064 | ពន្ធប្រថាប់ត្រាលើតម្លៃកិច្ចសន្យាចំពោះការផ្គត់ផ្គង់ទំនិញឬសេវា | 4.115,0 | 6.296,0 | 2.181,0 | 53,0% |
| | | 70065 | ពន្ធប្រថាប់ត្រាលើលិខិតមានលក្ខណៈគតិយុត្ត | 3.688,0 | 3.704,0 | 16,0 | 0,4% |
| | 7007 | | ពន្ធលើអចលនទ្រព្យ | 106.998,0 | 114.064,0 | 7.066,0 | 6,6% |
| | | 70071 | ពន្ធលើអចលនទ្រព្យរូបវន្តបុគ្គល | 96.038,0 | 103.524,0 | 7.486,0 | 7,8% |
| | | 70072 | ពន្ធលើអចលនទ្រព្យនីតិបុគ្គល | 6.646,0 | 5.658,0 | -988,0 | -14,9% |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 4.314,0 | 4.882,0 | 568,0 | 13,2% |
| ប្រភេទទី ២: ចំណូលមិនមែនសារពើពន្ធ | | | | 137.131,0 | 158.939,0 | 21.808,0 | 15,9% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 4.287,4 | 6.924,9 | 2.637,5 | 61,5% |
| | 7200 | | ផលនៃសម្បទាន និងការជួលដីធ្លី | 4.287,4 | 6.924,9 | 2.637,5 | 61,5% |
| | | 72004 | សម្បទានរ៉ែ | 2.208,0 | 5.009,0 | 2.801,0 | 126,9% |
| | | 72006 | ចំណូលពីចំណតរថយន្ត | 1.647,1 | 1.657,1 | 10,0 | 0,6% |
| | | 72007 | ចំណូលពីចំណតជលយាន | 303,4 | 249,3 | -54,1 | -17,8% |
| | | 72008 | ផលនៃការជួលដីធ្លីផ្សេងៗ | 128,9 | 9,5 | -119,4 | -92,6% |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 23.707,9 | 23.301,1 | -406,8 | -1,7% |
| | 7300 | | ផលទុនសហគ្រាសសាធារណៈរដ្ឋបាល សេវាដំណើរការ (រកចំណេញ) | 11.510,0 | 11.520,4 | 10,4 | 0,1% |
| | | 73008 | ផលទុនផ្សេងៗទៀត | 11.510,0 | 11.520,4 | 10,4 | 0,1% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 2.949,4 | 3.229,7 | 280,3 | 9,5% |
| | | 73027 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាននិងសេវាត្រួតពិនិត្យអនាម័យសត្វ | 1.417,0 | 1.366,7 | -50,3 | -3,5% |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1.532,4 | 1.863,0 | 330,6 | 21,6% |
| | 7303 | | ការជួលទ្រព្យសម្បត្តិអចល័ត | 57,0 | 57,0 | 0,0 | 0,0% |
| | | 73036 | ការជួលគ្រឹះស្ថានសាធារណៈនៅថ្នាក់ក្រោមជាតិ | 57,0 | 57,0 | 0,0 | 0,0% |
| | [illegible] | | [illegible]សេវាកម្ម | 1.943,0 | 1.035,0 | -908,0 | -46,7% |
| | | 73043 | [illegible]រិយោដី | 770,0 | 0,0 | -770,0 | -100,0% |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០១៧

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ទឹកប្រាក់ | ភាគរយ |
| | | 73044 | សេវាសំណង់ | 75,0 | 0,0 | -75,0 | -100,0% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 1.098,0 | 1.035,0 | -63,0 | -5,7% |
| | 7305 | | ការជួលទ្រព្យសម្បត្តិអចល័តផ្សេងទៀត | 7.248,5 | 7.459,0 | 210,5 | 2,9% |
| | | 73051 | ចំណូលពីសត្តឃាតដ្ឋាន | 864,6 | 937,5 | 72,9 | 8,4% |
| | | 73052 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | 1.541,4 | 1.631,5 | 90,1 | 5,8% |
| | | 73053 | ចំណូលពីកំពង់ចម្លង | 1.128,4 | 982,3 | -146,1 | -12,9% |
| | | 73054 | ចំណូលពីយៀត្រ៍ និងកន្លែងបែងចែកផលិតផល | 194,6 | 174,3 | -20,3 | -10,4% |
| | | 73055 | ចំណូលពីភាស៊ីផ្សារ | 3.519,5 | 3.550,6 | 31,1 | 0,9% |
| | | 73058 | ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗ | 0,0 | 182,8 | 182,8 | |
| **74** | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **3.394,7** | **3,0** | **-3.391,7** | **-99,9%** |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 6,0 | 3,0 | -3,0 | -50,0% |
| | 7402 | | ផលពីការទប់ស្កាត់ និងបង្ក្រាបអំពើគេចពន្ធគយ | 3.388,7 | 0,0 | -3.388,7 | -100,0% |
| **75** | | | **ការឧបត្ថម្ភ អំណោយ** | **105.741,0** | **128.710,0** | **22.969,0** | **21,7%** |
| | 7501 | | ឧបត្ថម្ភកធនពីថ្នាក់ជាតិ | 105.741,0 | 128.710,0 | 22.969,0 | 21,7% |



# ការគ្រប់គ្រងឆ្នាំ២០១៧

## តារាង "ខ១"

## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទទី១ មធ្យោបាយ និងសេវា | ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយ ផ្សេងៗ | ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី១ ការទូទាត់ ការខ្ចី | ប្រភេទទី២ អចលកម្ម |
| សរុបរួមចំណាយ | 20.184.457,0 | 13.050.686,0 | 9.841.807,7 | 342.294,0 | 2.106.923,8 | 307.235,0 | 452.425,5 | 7.133.771,0 | 665.514,0 | 6.468.257,0 |
| រដ្ឋបាលកណ្តាល | 11.989.033,2 | 9.139.819,2 | 6.100.533,8 | 342.294,0 | 1.938.619,6 | 305.946,3 | 452.425,5 | 2.849.214,0 | 665.514,0 | 2.183.700,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល | 216.345,2 | 216.345,2 | | | 216.345,2 | | | 0 | | 0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 3.910.866,8 | 3.910.866,8 | 3.741.273,9 | | 168.304,2 | 1.288,7 | | 0 | | 0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4.284.557,0 | | | | | | | 4.284.557,0 | | 4.284.557,0 |
| ក. វិស័យរដ្ឋបាលទូទៅ | 2.156.626,9 | 1.986.942,3 | 1.209.886,3 | | 472.774,5 | 304.281,5 | | 169.684,6 | | 169.684,6 |
| រដ្ឋបាលកណ្តាល | 1.852.283,3 | 1.840.283,3 | 1.063.316,0 | | 472.774,5 | 304.192,8 | | 12.000,0 | | 12.000,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល | 103.287,5 | 103.287,5 | | | 103.287,5 | | | 0,0 | | 0,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 146.659,0 | 146.659,0 | 146.570,3 | | | 88,7 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 157.684,6 | | | | | | | 157.684,6 | | 157.684,6 |
| ០១. ព្រះបរមរាជវាំង | 85.748,0 | 85.748,0 | 65.659,0 | | 19.880,0 | 209,0 | | 0,0 | | 0,0 |
